# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យា

## ស្តីពី

## ការវិនិយោគដាំដុះដំណាំកសិ-ឧស្សាហកម្ម និង ចិញ្ចឹមសត្វ

រវាង

## អនុគណៈកម្មការវិនិយោគខេត្តកំពង់ធំ

និង

## ក្រុមហ៊ុន ស៊ីវ ហ្គេក អ៊ិនវេសមេន

**<u>កិច្ចសន្យានេះធ្វើឡើងរវាង</u> :**

**អនុគណៈកម្មការវិនិយោគខេត្តកំពង់ធំ** តំណាងដោយឯកឧត្តមអភិបាលខេត្តកំពង់ធំ មានអាស័យដ្ឋានលេខ: ........ថេរវិថីស្ទឹងសែន និង ផ្លូវតេជោប៉ែន ទូរស័ព្ទលេខ: (៨៥៥) ៦២ ៩៦១ ២៨២ មានគណនីលេខ : ............... .................... .. .. .. ...........នៅធនាគារជាតិ នៃកម្ពុជាហៅថា ភាគី "ក" ។

ជាមួយនឹង

ក្រុមហ៊ុន **ស៊ីវ ហ្គេក អ៊ិនវេសមេន** ( SIV GUEK INVESMENT Co., Ltd ) មានស្នាក់ការ នៅភូមិ៥យុំ ជុប ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមទូរស័ព្ទលេខ (៨៥៥)១២ ៧៦៧ ២១១ Fax: ០៤២ ៣៩៦ ៧១៨ ដែលតំណាង ដោយលោកស្រី អ៊ុង-ស៊ីវហ្គេក នៃជាតិខ្មែរ ឋានៈប្រធានក្រុមហ៊ុនមានគណនីលេខ 0500305000040 នៅធនាគារកាណាឌីយ៉ា សាខាខេត្ត កំពង់ចាម ហៅថា ភាគី "ខ" ។

យោង :-ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់វិសោធន៍កម្មនៃច្បាប់វិនិយោគ នៃព្រះរាជាណាចក្រ កម្ពុជា

-ច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា

-តាមលិខិតលេខ ៤២៩/០៣៣កសក.នផ.ផក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ ។

-តាមលិខិតលេខ ១៨១៥.ស.ជ.ណ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-តាមលិខិតលេខ ៧២ សប្រទ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីសិទ្ធិប្រទានរបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ព្រះរាជាណាចក្រកម្ពុជាប្រទានសិទ្ធិជូនឯកឧត្តម ណាំ ទុំ អភិបាលខេត្ត និងជាប្រធានអនុគណៈកម្មាធិការវិនិយោគ ខេត្តកំពង់ធំ

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ មានដូចខាងក្រោមនេះ :

### ប្រការ១ : កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួនបួនរយប៉ែតសិបប្រាំបី(៤៨៨)

ហិកតា ដែលមានទីតាំងឃុំក្រយាក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ជូនទៅភាគី ៉ខ៉ កាន់កាប់ប្រើប្រាស់ធ្វើវិនិយោគ ដាំដំណាំកសិ-ឧស្សាហកម្ម និងចិញ្ចឹមសត្វ ។

១.១ ទីតាំង និងទំហំផ្ទៃដីខាងលើ ពីពេលនេះទៅ ហៅថា ៉ ទីតាំង៉ បានបញ្ជាក់កាន់តែច្បាស់ដោយមាន ឯកសារនានាភ្ជាប់ជា ឧបសម្ព័ន្ធនៃកិច្ចសន្យា ដូចខាងក្រោមនេះ :

-របាយការណ៍ស្តីពី លទ្ធផលចុះកំណត់ព្រំប្រទល់ដី និងធ្វើអង្កេតបញ្ហាផ្សេងៗទៀត ក្នុងតំបន់ដីសម្បទានចំនួន ៤.២៣៥ ហិកតារបស់ក្រុមហ៊ុន ស៊ីវ ហ្គេកអ៊ិនវេសមេន.ហ្គោលដេន ហ្វាម៉ឹងអ៊ិនវេសមេន . ហេង មាន អ៊ិនវេសមេន. អាន សុភីហ្វាម៉ីង( ខេមបូឌា) និងក្រុមហ៊ុន( ខេមបូឌា) ហ្វាម័រអ៊ិនវេសមេន ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០៧ របស់ក្រុមការងារ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហការជាមួយជំនាញ និងអាជ្ញាធរមូលដ្ឋាន ។

-គំនូសផែនទី និងបញ្ជីកូអរដោណេចង្អុលទីតាំងដីមួយ( ១ )កន្លែង ។

១.២ ប្លុកក្បាលដី និងទំហំផ្ទៃដី ដែលជាទីតាំងដីសម្បទានខាងលើនេះ ភាគី ៉ ខ ៉ ត្រូវសុំទៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីចុះបញ្ជី សមស្របតាម សារាចរលេខ ០៥ សរណន ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥ និងអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេលបី (៣ ) ខែ ក្រោយពីថ្ងៃ ចុះហត្ថលេខា នៃកិច្ចសន្យានេះ ។ ការចំណាយផ្សេងៗ សម្រាប់ការចុះបញ្ជីនេះ ជាបន្ទុក របស់ភាគី ៉ ខ ៉ ។

## ប្រការ២ : អំពីថិរៈវេលា

២.១ កិច្ចសន្យានេះមានរយៈពេលចិតសិប (៧០)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ សិទ្ធិនៃការកាន់កាប់ដីសម្បទាននឹងត្រូវប្រគល់ជូនបន្ទាប់ពីកិច្ចសន្យានេះចូលជាធរមានទៅតាមច្បាប់ជាធរមាន ។ សេចក្តីជូនដំណឹង បញ្ចប់កិច្ចសន្យាត្រូវផ្តល់ដំណឹងជាមុនចំនួនមួយ ( ០១) ឆ្នាំ ឬ នៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យា ។

២.២ ភាគី ៉ខ៉ មានសិទ្ធិសុំជួលបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេលចិតសិប (៧០)ឆ្នាំ។ រយៈពេលមួយ (០១)ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី ៉ ខ ៉ អាចសុំធ្វើវិនិយោគបន្តទៅទៀតហើយការបន្តអាចធ្វើឡើងទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាត ពីរាជរដ្ឋាភិបាលកម្ពុជាតាមសំណើររបស់ភាគី ៉ ក៉ ដោយយោលទៅតាមការអនុវត្តន៍កន្លងមករបស់ភាគី ៉ខ៉ និងដោយ មានការពិភាក្សាឯកភាពពីភាគី ៉ក៉ អំពីលក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី ។

## ប្រការ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និងកម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី ៉ ខ ៉ គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ច និងផែនការមេដែលក្រុមហ៊ុនត្រូវធ្វើដូចចំណុច ៧.៣ នៃមាត្រា ៧ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

៣.១ គោលដៅផលិតកម្ម-អាជីវកម្ម :

ព្រះរាជាណាចក្រកម្ពុជា
ស៊ីវ ហ្គេក អ៊ិនវេសមេន
SIV GUEK INVESTMENT
Co., Ltd.

**ប្រការ១៨ : ការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា**

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី.....០៧.....ខែ...ក.៣៣........ឆ្នាំ ២០០៧ ហើយត្រូវផុតកំណត់នៅថ្ងៃទី.....០៧ ខែ.ក.៣៣.....ឆ្នាំ ២០៧៧ ។

ធ្វើនៅកំពង់ធំ.ថ្ងៃទី......០៧......ខែ.ក.៣៣.ឆ្នាំ ២០០៧

**តំណាងភាគី "ខ"**

**ក្រុមហ៊ុន ស៊ីវ ហ្គេក អ៊ិនវេសមេន**

ព្រះរាជាណាចក្រកម្ពុជា
ស៊ីវ ហ្គេក អ៊ិនវេសមេន
SIV GUEK INVESTMENT
Co., Ltd.
ខេត្តកំពង់ធំ

**អ៊ុង_ស៊ីវហ្គេក**

**តំណាងភាគី "ក"**

**ប្រធានអនុគណៈកម្មការវិនិយោគខេត្ត**

**ណាំ_ធុំ**

**<u>កន្លែងតំកល់ឯកសារ</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- ក្រសួងឧស្សាហ៊កម្ម រ៉ែ និង ថាមពល
- ក្រសួងបរិស្ថាន
- តុលាការខេត្ត
- សាលាខេត្តកំពង់ធំ
- ខណ្ឌរដ្ឋបាលព្រៃឈើ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មន្ទីរបរិស្ថានខេត្ត
- មន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- មន្ទីរផែនការខេត្ត
- មន្ទីរឧស្សាហ៊កម្ម រ៉ែ និង ថាមពល
- មន្ទីរកសិកម្មខេត្ត កំពង់ធំ
- ភាគី "ក"
- ភាគី "ខ"
- កាលប្បវត្តិ-ឯកសារ

# ផែនទី ទីតាំងស្នើសុំដីសម្បទាន ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ




សញ្ញាសំគាល់

- ព្រំប្រទល់ស្នើសុំ
- ផ្លូវលំ
- ផ្លូវអតីតក្រុមហ៊ុនសម្បទាន
- ផ្លូវទឹក
- ខ្សែកម្ពស់

តំបន់ព្រៃឈើឆ្នាំ ២០០២

| | |
|---|---|
| ព្រៃស្រោង | ១៤ ហ.ត |
| ព្រៃល្បោះ | ៤២៧ ហ.ត |
| ព្រៃកម្ពស់ទាប | ១៧ ហ.ត |
| ដីកាប់ឆ្ការ | ៤៤ ហ.ត |
| ផ្ទៃដីសរុប | ៥០២ ហ.ត |




មាត្រដ្ឋាន ១ : ២៥.០០០

៥០០ 0 ៥០០ម

លេខ: ...
បានឃើញ និង បញ្ជូនមក
...
សន្ទុក, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ប្រធានការិយាល័យកសិកម្មស្រុក

លេខ: ...
បានឃើញ និង បញ្ជូនមក
...
ក្រយា, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ក្រយា ... (ហត្ថលេខា)

កែវ-ចេង

លេខ: ...
បានឃើញ និង បញ្ជូនមក
...
សន្ទុក, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ប្រធានការិយាល័យបរិស្ថានស្រុក

លេខ: ...
បានឃើញ និង បញ្ជូនមក
...
សន្ទុក, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីស្រុក

លេខ: ...
បានឃើញ និង បញ្ជូនមក
...
កំពង់ធំ, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ប្រធានមន្ទីរកសិកម្មខេត្ត

អ៊ឺ បុស្សរ័ត្ន

លេខ: ...
បានឃើញ និង បញ្ជូនមក
...
សន្ទុក, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
អភិបាលស្រុក

លឹម-ជាំស៊ុ

លេខ: ...
បានឃើញ និង ឯកភាព
កំពង់ធំ, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
អភិបាលខេត្ត

ឈាំ_ឆ្នាំ

លេខ: ...
បានឃើញ និង បញ្ជូនមក
...
កំពង់ធំ, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ប្រធានមន្ទីរបរិស្ថានខេត្ត

ហេង_ឃួត

លេខ: ...
បានឃើញ និង បញ្ជូនមក
...
កំពង់ធំ, ថ្ងៃទី ...ខែ...ឆ្នាំ ២០០៦
ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត

ឡឹត_ចន

# ផែនទី ទីតាំងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ីវ ហ្គេច ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ




សញ្ញាសំគាល់

- ចំណុចព្រំដី
- ព្រំប្រទល់ស្នើសុំ
- ផ្លូវលំ
- ផ្លូវទឹក
- ខ្សែរយៈកំពស់
- ព្រំប្រទល់ព្រៃរក្សាទុក

គំរបព្រៃឈើឆ្នាំ ២០០២

| | |
|---|---|
| ព្រៃស្រោង | ១៤ ហ.ត |
| ព្រៃផ្សេង១ | ៤២៧ ហ.ត |
| ព្រៃគុម្ពោតបៃតង | ១៧ ហ.ត |
| ដីពុំមានគំរបព្រៃ | ៤៤ ហ.ត |
| ផ្ទៃដីសរុប | ៥០២ ហ.ត |
| ផ្ទៃដីនៅសល់ | ៤៨៨ ហ.ត |

1(539709 1396509)
2(539641 1396655)
3(539628 1396840)
4(539694 1396919)
5(539826 1396919)
6(540008 1396900)




N

មាត្រដ្ឋាន ១ : ២៥.០០០

៥០០ 0 ៥០០ម